ការសម្ភាសរបស់លោកតា ផាន់ ភឿន

ក៖ អ្នកសម្ភាសគេឈ្មោះជាង ស៊ីអ៊ាវ

ខ៖ អ្នកទទួលការសម្ភាសឈ្មោះ ផាន់ ភឿន៕

ការសង្ខេបប្រវត្តិរបស់លោកតា ផាន់ ភឿន

លោកតា ផាន់ភឿន មានអាយុ៦០ឆ្នាំនៅក្នុងឆ្នាំ២០១៩ មានភេទ ប្រុស មានទីលំនៅបច្ចុប្បន្ននៅភូមិយបាត ឃុំក្បាលកោះ ខ័ណ្ឌច្បារអំពៅ រាជធានីភ្នំពេញ៕

ក៖ ចឹងជាដំបូងខ្ញុំអរគុណច្រើនតាដែរបានអោយខ្ញុំពិភាក្សាជាមួយតាទាក់ទងពីប្រវត្តិរបស់តា

ហើយការសម្ភាសទាំងអស់នេះត្រូវរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថា

BYUពីហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីទុកអោយកូនចៅជំនាន់ក្រោយពួកគាត់បានស្គាល់ហ្នឹងបានដឹងពីប្រវត្តិឪពុកម្តាយ

ហ្នឹងអ្នូនតា?

ខ៖ បាទ!

ក៖ ចឹងសំរាប់តាយល់ព្រមដើម្បីអោយចៅងាក់ការសម្ភាសទាំងអស់ហ្នឹងទៅក្នុងផបសាយសាលាដើម្បីតំកល់ទុកអោយកូនចៅជំនាន់ក្រោយពួកគាត់បានស្គាល់បានដឹងទេតា?

ខ៖ បាទ!

ក៖ បាទចឹងសំរាប់ខ្ញុំជាអ្នកសម្ភាសតាខ្ញុំមានឈ្មោះថាជាង ស៊ីអ៊ាវ ហើយថ្ងៃខែដែរខ្ញុំសម្ភាសតាគឺនៅថ្ងៃហ្នឹងថ្ងៃទី៣០ហេសតា?

ខ៖ ថ្ងៃប៉ុន្មានអើថ្ងៃ៣០។

ក៖ ថ្ងៃ៣០ខែ១ឆ្នាំ២០១៩ ហើយការសម្ភាសទាំងអស់ហ្នឹងគឺធ្វើនៅភូមិយបាតចុះ...?

ខ៖ សង្កាត់ក្បាលកោះ។

ក៖ សង្កាត់ក្បាលកោះចុះខ័ណ្ឌ?

ខ៖ អើខ័ណ្ឌអើច្បារអំពៅ។

ក៖ ខ័ណ្ឌច្បារអំពៅ?

ខ៖ បាទ!

ក៖ រាជធានីភ្នំពេញណេះតា?

ខ៖ បាទ!

ក៖ ចឹងសំរាប់តាឈ្មោះពេញទាំងត្រកូលរបស់តាម៉ងឈ្មោះអីគេតា?

ខ៖ ផាន់ ភឿន។

ក៖ ផាន់ ភឿន?

ខ៖ បាទ!

ក៖ ចុះមានឈ្មោះហៅក្រៅអត់តា?

ខ៖ អត់មានឈ្មោះតែភឿនហ្នឹងម៉ងហៅតែអាភឿនៗរហូត។

ក៖ អ៊ុំចុះកាលពីក្មេងធ្លាប់មាននរណាគេហៅឈ្មោះផ្សេងទេតា?

ខ៖ អត់ទេហៅអាកឺន។

ក៖ ហៅកឺន?

ខ៖ បាទ!

ក៖ អ៊ុំចុះ...?

ខ៖ គេហៅលេង។

ក៖ បាទតាបាទចុះ...?

ខ៖ នៅតូចៗគេហៅអាកឺនៗ។

ក៖ ចុះសព្វថ្ងៃតាអាយុប៉ុន្មានទៅតា?

ខ៖ ហុកមួយ។

ក៖ ហុកមួយ?

ខ៖ បាទ!

ក៖ អ៊ុំអាយុច្រើនហើយហោស?

ខ៖ អើ!

ក៖ អ៊ុំចុះតាកើតនៅថ្ងៃខែឆ្នាំណាតាចាំទេតា?

ខ៖ ហាច្រាំពីរ។

ក៖ មួយពាន់ច្រាំបួនរយហាច្រាំពីរ?

ខ៖ បាទ!

ក៖ អ៊ុចុះអើតាកើតនៅណាតា?

ខ៖ នៅព្រៃរឡៃទៅហ្នឹងមួយគីឡូទៀត។

ក៖ អ៊ុហ្នឹងភូមិអីគេតាភូមិហ្នឹងដែរមែន?

ខ៖ ភូមិក្បាលកោះអាហ្នឹងក្បាលកោះ។

ក៖ អ៊ុភូមិឃុបាត ឃុំក្បាលកោះដដែលហោស?

ខ៖ អើអានោះភូមិធំអានោះភូមិធំផ្ទះគាត់នៅខាងប្រពន្ធនៅនេះ។

ក៖ អ៊ុនៅនេះហោស?

ខ៖ បាទ!

ក៖ ចុះតាមានបងប្អូនបង្កើតចំនួនប៉ុន្មាននាក់?

ខ៖ មើលប្រាំបីនាក់បងប្អូនប្រាំបីនាក់។

ក៖ ប្រាំបីនាក់ហោសតា?

ខ៖ ហើយស្រីបីប្រុសប្រាំ។

ក៖ ចុះតាអាចប្រាប់ឈ្មោះពួកគាត់បានទេ?

ខ៖ បានតើ!

ក៖ គាត់ឈ្មោះអីគេខ្លះតា?

ខ៖ ឈ្មោះទុង ឈ្មោះអើធី ឈ្មោះអារី អារីពៅគេស្រីអ៊ុំប្រុស។

ក៖ បាទតាបាទចុះឈ្មោះអីផ្សេងទៀតតា?

ខ៖ អត់ទេហៅអារីៗវាពៅគេហាសឈ្មោះវាអារីចឹងម៉ង។

ក៖ អ៊ុចុះ...?

ខ៖ ហៅ!

ក៖ មានអ្នកស្លាប់អត់តាបងប្អូនតា?

ខ៖ អត់ទេ!

ក៖ អត់ទាន់មានអ្នកស្លាប់ទេហោសតា?

ខ៖ អត់ល្អនៅទាំងអស់ប្រាំបីនៅទាំងប្រាំបីនាក់។

ក៖ ចុះតាកូនទីប៉ុន្មានកូនបងគេរីកូនពៅគេ?

ខ៖ កូនទីពីរទីពីរអាប្រុសយើងបងគេហាស!

ក៖ អ៊ុបាទ!

ខ៖ ហាយបងស្រីខ្ញុំទីមួយពីដើមគាត់ធ្វើផុងគុយទាវដែរបងស្រីខ្ញុំហ្នឹងគាត់ពីដើមគេអ្នកមានគេយកគាត់ធ្វើប្រពន្ធចុងហោស!

ក៖ អ៊ុ!

ខ៖ តែឥឡូវគាត់ធូរធាគាត់បានកូនទៅអាមេរិច។

ក៖ អ៊ុរួចចុះអើតាគិតថាបងប្អូនរបស់តាសព្វថ្ងៃគាត់អ្នកនៅណាឥឡូវ?

ខ៖ នៅកំពង់ធំបាទ!

ក៖ នៅខាងនោះទាំងអស់?

ខ៖ បាទនៅកំពង់ធំ។

ក៖ រួចចុះប្អូនៗទៀត?

ខ៖ ខ្លះនៅស្រែនៅខាងកំពង់ស្ពឺម្នាក់ហ្នឹងបងគាត់ឌុបទៅធ្វើប៉ុនអត់សូវបានទេមីណុងប៉ុនពាក់អាវទៀតហាស!

ក៖ បាទ!

ខ៖ ខ្ញុំជាងផ្ទះមុន ជាងកំបោរជាងឈើខ្ញុំចេះទាំងអស់។

ក៖ អ៊ុតាចេះធ្វើដែរ?

ខ៖ បាទប៉ុនឥឡូវខ្ញុំចាស់ហើយលែងធ្វើលែងអីហើយ!

ក៖ អ៊ុ!

ខ៖ ឥឡូវចប់ហើយមានធ្វើអីទៀតតែប៉ុណ្ណឹង។

ក៖ អ៊ុចុះតាគិតថាអើជំនាញអីដែរតាចេះធ្វើទៅចឹង?

ខ៖ រាល់ថ្ងៃ?

ក៖ បាទ!

ខ៖ លែងធ្វើអីបានកូនចិញ្ចឹមតើរាល់ថ្ងៃមានធ្វើអីទៀត។

ក៖ អ៊ុចុះកាលពីមុនៗកាលនៅតូចតាធ្វើអីទៅ?

ខ៖ មុនធ្វើជាងហើយធ្វើជាងកំបោរខ្ញុំធ្វើជាងសំណង់ទៅ។

ក៖ អ៎ូ!

ខ៖ ខ្ញុំម៉ៅគេធ្វើទៅខ្ញុំម៉ៅគេធ្វើរហូតណុងឥឡូវបានកូនប្រុសមួយគេជាងដែរគេចេះច្រើនហាស!

ក៖ គេចេះតពីតាហោស?

ខ៖ អត់ទេគេចេះខ្លួនគេម៉ងគេរៀនទៅបែកហាស!

ក៖ អ៎ូ!

ខ៖ រួចបើខាងជាងសំណង់ណែគ្រាន់វាច្បាស់ជាងខ្ញុំបួកស្លីវាលាបស្អាតៗជាងខ្ញុំហាស!

ក៖ អ៎ូបាទចុះអើតាឪពុករបស់តាឈ្មោះអីគេតា?

ខ៖ ឈ្មោះផុន។

ក៖ ឈ្មោះអីគេផុនតា?

ខ៖ ណែផាន់ ផុន។

ក៖ ផាន់ ផុន?

ខ៖ ណែដល់ខ្ញុំផាន់ ភឿនវិញ។

ក៖ អ៎ូចុះឥឡូវគាត់អាយុប៉ុន្មានទៅតាដងអត់?

ខ៖ អើគាត់ស្លាប់បាត់ហើយប៉ុនចូលគាត់ចូលបែតដែរ។

ក៖ ចូលបែតណោះតា?

ខ៖ ដល់បើយាយខ្ញុំបែតក្រាស់យាយខ្ញុំបែតប្រាំបីហាសគាត់ស្លាប់ឃ្លេរហើយនៅតែយាយទេ។

ក៖ អ៎ូយាយនៅទៀតហោស?

ខ៖ នៅនៅយាយតែគាត់ទៅអីប្រែហោសអីនៅខាងកំពង់ស្ពឺ។

ក៖ អ៎ូ!

ខ៖ ប្អូនស្រីខ្ញុំគាត់ជួយពាក់អោយ។

ក៖ អ៎ូចុះយាយគាត់ឈ្មោះអីគេម្តាយរបស់តា?

ខ៖ ម្តាយខ្ញុំឈ្មោះយាយងួយ។

ក៖ យាយងួយ?

ខ៖ បាទ!

ក៖ អ៎ូចុះតាគិតថាអើយាយដល់ឥឡូវគាត់អាយុប៉ុន្មានតាបែតប្រាំបួនបែតប្រាំបីបែតប្រាំបួនហើយ!

ក៖ អ៎ូអាយុច្រើនហោស?

ខ៖ ប្រពន្ធឯងគាត់បែតដែរគាត់ឆ្នាំមមី។

ក៖ អ៎ូចុះតាគិតថាអើឪពុករបស់តាកាលគាត់នៅរស់គាត់ធ្វើអីគេចិញ្ចឹមជីវិតកូនចៅតា?

ខ៖ គាត់ធ្វើចំការភ្លួរដីកាន់ខ័ណ្ឌលទៅហើយគាត់ធ្វើពុកឡើងត្នោតឡើងអីឡើងដើមឈើគាត់ឡើងដើមឈើគាត់ម៉ៅគេពីដើមម៉ៅឡើងផ្ទះហាស!

ក៖ អ៎ូចុះម្តាយរបស់តាវិញ?

ខ៖ ម្តាយខ្ញុំគាត់ធ្វើចំការគាត់អត់ធ្វើធ្វើតែចំការរហូតពីដើមដាំត្រសក់ស្រូវហាស!

ក៖ បាទតា!

ខ៖ គេដាំត្រសក់ស្រូវប៉ុនណាក្រោកឡើងខ្ទេរហូត។

ក៖ អ៎ូ!

ខ៖

មិនដូចឥឡូវណាពីដើមដាក់តែប៉ែងបោះដោតៗចោលដាក់តែអាចម៍គោតិចទៅផ្លែបេះបួនដប់បោតម៉ូយអើខាងស្វាយម៉ៀងគេចិញ្ចឹយកទៅហាសឪពុកកាន់យកទៅរហូតហ្នឹង!

ក៖ បាទតាចុះតាគិតថាអើឪពុកម្តាយរបស់តាតាស្គាល់ប្រវត្តិគាត់កាលនៅក្មេងទេ?

ខ៖ ស្គាល់ដែរគាត់ធ្វើតែចំការរហូតពុកខ្ញុំគាត់ឡើងត្នោតពីដើមហាស!

ក៖ អ៎ូ!

ខ៖ គាតចេះឡើងត្នោតទៀតហើយដើមឈើក៏គាត់កាប់បេះផ្លែឈើអីក៏គាត់ឡើងបេះដែរ។

ក៖ អ៎ូ!

ខ៖ គាត់តាំងពីឈឺមកគាត់មិនសូវចាំទេ។

ក៖ អ៎ូ!

ខ៖ គាត់ឈឺហ្នឹងហើយគាត់ដឹងមិនថាមិនដឹងទេប៉ុនគាត់ឈឺទៅគាត់លែងចាំ។

ក៖ បាទ!

ខ៖ លែងចងចាំហាសណាស់ពីដើមហ្នឹងហើយ!

ក៖ អត់អីទេគាអាចចាំតែអ្វីដែរគាត់អាចនិយាយបានចឹងហាស?

ខ៖ ចឹងដែរ!

ក៖ បាទ!

ខ៖ អាណាចាំនិយាយចេញហាសអាណាមិនចាំអត់ទៅ។

ក៖ បាទចុះតាគិតថាអើយាយតាខាងឪពុកតាស្គាល់ឈ្មោះគាត់អត់?

ខ៖ អត់ឪពុកនៅស្រែ។

ក៖ តែគាត់ឈ្មោះអីគេយាយតាខាងឪពុកតាទៀតហាស?

ខ៖ យាយខាងតាផុនឈ្មោះអីឈ្មោះអើដឹងស្គាល់តា តាឈ្មោះតាផាន់ហែងយាយយាយអឹង ឈ្មោះយាយអឹងអីទេ។

ក៖ អ៎ចុះ..?

ខ៖ ប៉ុន្តែគាត់...?

ក៖ យាយតាខាងម្តាយវិញ?

ខ៖ អើយាយងួយ។

ក៖ យាយងួយហ្នឹងយាយឪពុកម្តាយយាយងួតឈ្មោះអីគេ?

ខ៖ គាត់ឈ្មោះលុក ផុន។

ក៖ លុក ផុន?

ខ៖ អើឈ្មោះអើលោកទីម។

ក៖ លោកទីម?

ខ៖ បាទ!

ក៖ ចុះយាយ?

ខ៖ យាយគាត់នៅដល់រាល់ថ្ងៃគាត់ទៅនៅប៉ែស្រដាមួយកូនប្អូនទៅណាស់។

ក៖ ម្តាយយាយងួយហាស?

ខ៖ អត់ទេយាយតាអឿនឯងហាស យាយតាអឿនឯង។

ក៖ ម្តាយយាយងួយឈ្មោះអីគេ?

ខ៖ ឈ្មោះលុក ទីម។

ក៖ ម្តាយម្តាយឈ្មោះអីគេ?

ខ៖ ឈ្មោះយាយទីមគាត់ស្លាប់អស់ហើយណាស់។

ក៖ អ៎!

ខ៖ គាត់អើស្លាប់តាំងពីចិតបីហោស!

ក៖ ពិបាកចាំអត់អីទេចុះចឹងតាមករស់នៅហ្នឹងយូរនៅតា?

ខ៖ តាំងចិតប្រាំបួនមកនៅហ្នឹងរហូត។

ក៖ អ៎!

ខ៖ នោះផ្ទះគាត់។

ក៖ ចុះតាពីមុនតានៅណាទៅចឹង?

ខ៖ ទៅវត្តតិចទៅគេហៅហ្នឹងចូលផ្លូវជនបទហើយហ្នឹង!

ក៖ អ៎!

ខ៖ អាលែងអានេះចូលក្រុងតាំងគេអភិវឌ្ឍន៍គេចូលក្រុង។

ក៖ បាទតាចុះតាគិតថាអើប្រពន្ធរបស់តាឈ្មោះអីគេតា?

ខ៖ ប្រពន្ធខ្ញុំឈ្មោះអើពុម។

ក៖ ពុម?

ខ៖ សុខស៊ីពុម។

ក៖ សុខស៊ីពុម?

ខ៖ បាទ!

ក៖ ចុះតាមានកូនប៉ុន្មាននាក់ឥឡូវតា?

ខ៖ កូនខ្ញុំប្រាំបីនាក់អើប្រាំមួយនាក់ប៉ុនងាប់អស់មួយសល់ប្រាំ។

ក៖ អ៎គាត់ងាប់គាត់ស្លាប់ដោយសារអីតា?

ខ៖ លង់ទឹក។

ក៖ អ៊ុំគាត់នៅកូនទីប៉ុន្មានស្លាប់ហ្នឹង?

ខ៖ អាហ្នឹងទីបី។

ក៖ កូនទីបីហោស?

ខ៖ បាទ!

ក៖ នរណាគេលង់ទឹកតាអឿន?

ខ៖ ឈ្មោះអានេះងាប់បាត់ហើយពុះពីវត្តទៅទៀតហោសចុះវាក្នុងចែតដីទុកចោលទុកមើលទៅ។

ក៖ អ៊ុំ!

ខ៖ អុចធួបអុចអីនៅហ្នឹងទៅ។

ក៖ ចុះតាអាចប្រាប់ឈ្មោះកូនរបស់តាថាពួកគាត់មានឈ្មោះអីខ្លះអត់តា?

ខ៖ ប្រាប់បានអាមួយឈ្មោះសុភាបងគេអាភា អាភាមកភាភ័ស អាភ័សមានកូនមានចៅបីហើយតាមានចៅបីហើយណាស់!

ក៖ បាទ!

ខ៖ តែសុទ្ធតែស្រួលដែរពៅគេម៉្លេបចំគេដណ្តឹងហើយប៉ុនមិនទាន់ការគ្រាន់ដណ្តឹងចោលសិនហាស!

ក៖ អ៊ុំអាភា អាភ័ស ហើយពីណាទៀត?

ខ៖ អើ!

ក៖ កូនៅប៉ុន្មាននាក់ហ្នឹង?

ខ៖ មីញឹក អាយួនកុំនិយាយជាមួយអាយួន អាយួនវាប៉ដេវាខ្មើយ។

ក៖ អត់អីទេអាយតែកូនតា?

ខ៖ ឯងនេះគ្រាន់ប្រាប់ប៉ុណ្ណឹងបាន។

ក៖ ហើយចុះអើកូនតាមានគ្រួសារប៉ុន្មាននាក់ហើយឥឡូវ?

ខ៖ និយាយទៅពីរហើយពីរ។

ក៖ កូនពីរនេះ?

ខ៖ បាទ!

ក៖ អើបងភា ហ្នឹងបងភ័ស?

ខ៖ អត់ទេអាភាអត់មានទេភានៅផ្ទះដែរវានៅបងគេហាសតែវាអត់យកប្តីយកអីទេគេចង់បានវាតែវាអត់យក។

ក៖ អ៊ុំម៉េចចឹង?

ខ៖ វាអត់និស្ស័យជាមួយប្តីម៉ង។

ក៖ អ៊ុំ!

ខ៖ អានេះកូនខ្ញុំដែរនេះអាហ្នឹងជាងអ៊ុតខោអាវអ៊ុតអីវាអ៊ុតអាយរហូតធ្វើសក់ធ្វើអីស្រី។

ក៖ អ៊ុំ!

ខ៖ ជំនាញវាហ្នឹងលុយបានមកតែវាទេអត់លុយសុំវាទៅ។

ក៖ បាទតាចុះតាសព្វថ្ងៃតានៅជាមួយកូនប៉ុន្មាននាក់តា?

ខ៖ នៅទាំងអស់គ្នាហ្នឹង!

ក៖ តានៅជុំជាមួយកូនម៉ង?

ខ៖ បាទ!

ក៖ កូនបែកប៉ុន្មាននាក់ទៅ?

ខ៖ បែកតែអាភ័សមួយអាភ័យមានប្រពន្ធចៅបានៅបី។

ក៖ អ៊ុំ!

ខ៖ ហើយស្រួលដែរមានលុយអាយទេអត់ទេរាល់ថ្ងៃមានធ្វើអីទេហូបតែកាហ្វេហើយហូបបាយទៅហើយចឹងទៅបានកូនចិញ្ចឹមទៅ។

ក៖ អ៊ុំ!

ខ៖ ច្រើនចក់បារាំងថ្នាំខ្លាំងបារីអីបារីសេកអត់ជក់តែអាហ្នឹងថ្នាំខ្លាំងសុទ្ធតែសង្កែខ្ញុំជក់តែអាហ្នឹង!

ក៖ ជក់ឡើងខ្មៅធ្មេញអស់ហើយ ជក់ឡើងខ្មៅធ្មេញ?

ខ៖ ធម្មតារបស់ខ្ញុំលេងសើចអីសេកអីខ្ញុំអត់ជក់ខ្ញុំមានដែរតែអត់ជក់ជក់តែបារីសង្កែហែងទៅដល់ណាទៅទៅសង្កែ។

ក៖ បាទ!

ខ៖ វាឆ្ងាញ់។

ក៖ បាទចុះអើប្រពន្ធតាវិញ?

ខ៖ ប្រពន្ធខ្ញុំ...!

ក៖ គាត់ធ្វើអីគេឥឡូវហាស?

ខ៖ អត់ធ្វើអីនៅមើលចៅមើលដាំបាយអោយខ្ញុំហូបហ្នឹងរាល់ថ្ងៃតែប៉ុណ្ណឹង។

ក៖ អ៎ចុះពីមុនគាត់ធ្វើអីគេទៅ?

ខ៖ គាត់ឈឺដែរ!

ក៖ គាត់ឈឺដែរហោស?

ខ៖ ពីមុនគាត់ធ្វើការធ្វើដាំដំឡូងអោយតែឥឡូវគាត់លែងដាំហើយដីលក់អោយគេអស់ហើយ!

ក៖ បាទ!

ខ៖ ហ្នឹងហើយគាត់លើសជាតិស្ករ។

ក៖ អ៎ចុះអើតាគិតថាតាការអស់ប៉ុន្មានឆ្នាំហើយឥឡូវ?

ខ៖ តាំងការតាំងពីអាយុម៉្លេះមួយដែរហើយឥឡូវហុកមួយហើយសែសិបឆ្នាំហើយ!

ក៖ អ៎ចឹងតា...?

ខ៖ បាទ!

ក៖ តាមានចៅប៉ុន្មាននាក់ហើយតា?

ខ៖ បីចៅបី។

ក៖ ចៅបីនាក់ហើយហោស?

ខ៖ បាទស្រីពីរប្រុសមួយ។

ក៖ តែចៅធំៗហើយណេះតាណេះ?

ខ៖ ធំៗហើយពៅគេធំហើយ!

ក៖ អ៎!

ខ៖ ហើយស្រួលដែរអោយតែប្រាំរយចប់អាតូចវាចាយចេះទារលុយមានលុយអោយវាអត់ហីទៅវាមិនដែរថាតាវ៉ា។

ក៖ អ៎បាទចុះតាគិតថាតាអាចប្រាប់អីចៅពីការលំបាករបស់តាពីក្មេងហាសតាធ្លាប់ធ្វើអីគេខ្លះពីជំនាន់ប៉ុលពតលុនណុលអីចឹងហាសតា?

ខ៖ ខ្ញុំពួកខ្ញុំធ្វើតែជាងសំណង់តាមអារយើងធ្វើម៉្លេបឥដ្ឋម៉្លេបអីហ្នឹងពីដើមធ្វើចឹង។

ក៖ ចុះកាលជំនាន់លុនណុលតា?

ខ៖ លុនណុលអាហ្នឹងខ្ញុំនៅលីវទេអាហ្នឹងខ្ញុំ!

ក៖ ធ្វើអីជាមួយយាយ?

ខ៖ ដាំបន្លែ។

ក៖ ដាំបន្លែហោស?

ខ៖ បាទដាំប៉េងប៉ោះយើងត្រឡាច ប៉េងប៉ោះហើយតែប៉ុណ្ណឹង។

ក៖ កាលជំនាន់ហ្នឹងមានគ្រាប់ផ្លោងណោះតាហី?

ខ៖ មានណា!

ក៖ រួចចុះពេលហ្នឹងយើងទៅនៅណាទៅ?

ខ៖ គេទៅឧបម៉ាគេមកដល់ហ្នឹងរួចនៅកោះទៀតទៅប៉ុន្តែស្រួលដែរកាលណុងរស់តាមដំណើរ។

ក៖ អ៎!

ខ៖ កាលជំនាន់ណុងអត់ទាន់ចេះជក់បារីទេទើបចេះបច្ចុប្បន្នហ្នឹងមុនបារីខ្ញុំអត់ចេះជក់ដល់ពេលឥឡូវខ្ញុំចេះជក់ពីមុនខ្ញុំអត់ចេះទេ។

ក៖ អ៎បាទតាចុះតាគិតថាកាលជំនាន់ណុងអើជំនាន់លុនណុលឪពុកម្តាយតារកស៊ីអីគេទៅ?

ខ៖ គាត់ធ្វើចំការ។

ក៖ គាត់ធ្វើចំការហោស?

ខ៖ អើ!

ក៖ ប៉ុន្តែ...?

ខ៖ តាគាត់ទៅភ្ជួរដីស្រូវគាត់នេះភ្ជួរដី។

ក៖ អ៎!

ខ៖ ហើយឯងធ្វើតែចំការ។

ក៖ ធ្វើចំការនៅក្រោយហោស?

ខ៖ ពេលណុងស្រួល។

ក៖ អ៎បាទ!

ខ៖ កាលណុងស្រួលហាសអូនអើយពីដើមទឹករហូតឥឡូវគេចាក់ច្រើនហាសប៉េងប៉ោះមិនបាច់ដាំច្រើនទេ។

ក៖ បាទ!

ខ៖ ដាក់តែនេះដាក់តែអាចម៍គោមួយដុំទៅបេះបែាងទាំងតៅហោស!

ក៖ អ៎ូបាទ!

ខ៖ ដាំត្រឡាច ដាំប៉េងប៉ោះ ដាំដំឡូងឈើដំឡូងអីហ្នឹងហាស!

ក៖ អ៎ូបាទយាយ!

ខ៖ ដើមពោតអីហ្នឹង!

ក៖ បាទយាយ!

ខ៖ ធ្វើតែចឹងទេជំនាន់ម្តាយគាត់ហ្នឹង!

ក៖ បាទ!

ខ៖ រាល់ថ្ងៃអត់មានការងារអីធ្វើទេ។

ក៖ បាទ!

ខ៖ ពុកខ្ញុំជំនាញខាងដើមឈើគាត់កែឡើង។

ក៖ បាទ!

ខ៖ ហើយដើមគគីក៏គាត់ឡើងរួចទីមួយរហូតចុះគាត់អ្នកឡើងត្នោតគាត់ឡើងត្នោតហាស!

ក៖ បាទ!

ខ៖ ដល់ហើយគាត់ជំនាញរបស់គាត់គាត់ឡើងធ្វើអីចាស់ៗរកគាត់កាប់ទៅ។

ក៖ អ៎ចុះតាគិតថាអើចូលដល់ជំនាន់ប៉ុលពតវិញពេលណុងគេជំលាសតាទៅណា?

ខ៖ ខ្ញុំនៅយាមគៀនស្វាយហ្នឹងម៉ងជំនាន់អាពតនៅគៀនស្វាយហ្នឹងដែរប៉ុនអត់ទៅណាហាស!

ក៖ បាទ!

ខ៖ ដល់ហើយយើងយុវជនហាសបានបានប្រពន្ធខ្ញុំមកធ្វើអង្រួន។

ក៖ អ៎ប៉ុន្តែកាលជំនាន់ប៉ុលពតហ្នឹងគេអោយតាធ្វើអីគេខ្លះហើយតាមានការលំបាកអីពេលជំនាន់ប៉ុលពតតា?

ខ៖

ប៉ុលពតធ្វើដូចគេដូចឯងដែរគេអោយធ្វើអីធ្វើទៅអត់ចេះភ្លេដីគេអោយភ្លេដីកាលណុងគេអោយកាន់ក្របីហាសអោយកាន់មិនចេះទេកាន់ទៅបាទរបបគេអោយហូបទៅដែងចេះហ្នឹង គេដោយកាន់ទង្គ័ល កាន់គោកាន់ក្របីចឹងគេអោយយើងចេះចេះភ្លេៗទៅបើមិនអីដែរជំនាន់ណុង គេអត់ជំលាសទៅណាទេអត់ទៅណាទេនៅហ្នឹងបាទនៅហ្នឹងរហូត។

ក៖ អ៎ចុះតាគិតថាចឹងពេលជំនាន់ប៉ុលពតគេអោយនៅជាមួយបងប្អូនអត់តា?

ខ៖ ខុសគ្នានៅចឹងប៉ុនគ្រាន់គេនៅយុវជនដាក់ដោយយុវជនទៅយើងនារីដាក់ដោយនារីដាក់ដោយនារីទៅ។

ក៖ អ៎!

ខ៖ គេដាក់ចឹងតែយើងគ្រាន់តែយើងហើយទើបមកពីណាយាយខំដើរក។

ក៖ រួចចុះប្អូនរបស់តាពេលណុងគេអោយទៅណាតា?

ខ៖ នៅផ្ទះដែរប៉ុន្តែគ្រាន់ថា គ្រាន់ថាគេដាក់ដោយតាមក្រុមម៉ាកុមារចឹងទៅ។

ក៖ បាទតា!

ខ៖ នេះក្រុមកុមារក្រុម...!

ក៖ ហើយចុះពេលណុងតាអាយុប៉ុន្មានតា?

ខ៖ ខ្ញុំដប់ប្រាំបីដប់ប្រាំបួនដែរជំនាន់ណុង។

ក៖ ប្រាំបីបួន ប៉ុន្មានដប់ប្រាំបីដប់ប្រាំបួនឆ្នាំ?

ខ៖ ដល់ហើយកាលជំនាន់អាពតណុងធ្វើតាគេទៅ។

ក៖ ប៉ុន្តែចឹងតាចូល..?

ខ៖ អាល៎ែង...!

ក៖ កងយុវជនណេះតាណេះ?

ខ៖ បាទដល់ហើយយុវជនខ្ញុំនៅតូចជាងគេជំនាន់យុវជនហាសមានទៅធំប៉ុន្មានទេទេគេដាក់តាមក្រុមឧទាហរណ៍ថាទូរស័ព្ទដៃចឹង!

ក៖ បាទ!

ខ៖ យើងតូចជាងគេយុវជនម្នាក់ចឹងទៅ។

ក៖ ប៉ុន្តែគេជំលាសតាទៅណាផ្សេងហើយអោយតាធ្វើអីផ្សេងទៀតអត់?

ខ៖ អត់ជំនាន់អាពតនៅតាមវីរៈគេតាមវីរៈពីរ។

ក៖ ចុះចឹងពិបាកអត់តាពេលជំនាន់ប៉ុលពត?

ខ៖ ពិបាកការខំឡើងយើងចឹងហើយតែអ៎កាលណុងសំបូរត្រីសំបូរអីចេះតែរកហូបហាសណាស់ប៉ុនពីដើមសំបូរត្រីមានដូចឥឡូវណាពីដើមសុទ្ធតែអណ្តែងត្រីទូក ត្រីទូកប៉ុនកដៃហ្នឹងចាប់ដៃហូបហាស!

ក៖ អ្ហ៎រចុះតាគិតថាអីរបបអាហារពេហ្នឹងគេអោយហូបអីគេតា?

ខ៖ តាមរបបគាត់។

ក៖ គេអោយតាហូបអីគេទៅជំនាន់ណុង?

ខ៖ ហាស!

ក៖ គេអោយតាហូបអីគេទៅជំនាន់ណុង?

ខ៖ មាននេះទៅដូចថាបាយរបបយើងនេះទៅហើយ...!

ក៖ ចុះតាគិតថាអីពេលដែរដាច់ប៉ុលពតហាសតា តាពេលដែរដាច់ប៉ុលពតហាស?

ខ៖ បាទ!

ក៖ ពេលណុងតាទៅណាទៅរស់នៅណាទៅ?

ខ៖ អាពតហើយខ្ញុំយកកូនមក។

ក៖ យកប្រពន្ធហោស?

ខ៖ បាទយកប្រពន្ធហាសប្រពន្ធមិញហ្នឹង!

ក៖ អ៎ដល់ពេលតាយកប្រពន្ធមកបានរស់ពេលហ្នឹងដាច់ប៉ុលពតថ្មីៗតារកស៊ីអីគេតា?

ខ៖ ខ្ញុំធ្វើជាងសំណង់។

ក៖ ជាងសំណង់ហោសតា?

ខ៖ បាទ!

ក៖ តាទៅធ្វើដល់ណាតា?

ខ៖ ធ្វើការធ្វើទៅធ្វើផ្ទះម៉្លេបឥដ្ឋម៉្លេបទៅ។

ក៖ តាធ្វើកូនជាងគេហែងតាម៉ៅខ្លួនឯង?

ខ៖ ម៉ៅខ្លួនឯងធ្វើបណ្តោយ។

ក៖ អ៎ចឹងមានន័យថាពីមុនប៉ុលពតតាចេះធ្វើសំណង់ហើយហើយ?

ខ៖ អត់ទេដល់ពេលបែកអាពតមកចេះតែម៉្លេនធ្វើទៅណាស់យើងចេះឆ្ពោតចឹងខ្ញុំចេះម៉្លេបទៅណាស់។

ក៖ បាទតា!

ខ៖ ដល់ហើយយើងធ្វើទៅអាជាងកំបោរមុនដំបូងជាងកំបោរក៏មិនចេះជាងឈើក៏មិនចេះ។

ក៖ ចុះមួយថ្ងៃតាបានប៉ុន្មានតាធ្វើជាងសំណង់ចឹង?

ខ៖ តាមសៀវភៅដែរជួនណាថាលុយពីដើមហ្នឹងប៉ុន្មានឧបម៉ាថាមួយម៉ឺនអីប៉ុនលុយតាមសៀវភៅសប៉ុនលុយ។

ក៖ រួចចុះអីចឹងមានន័យថាប្រពន្ធតាពេលដាច់ប៉ុលពតថ្មីៗគាត់ធ្វើអីគេតា?

ខ៖ មុនដំបូងគាត់បង្ហូរស្រាអីឡូអីហាសដល់ពេលគាត់ដល់ពេលគាត់ធ្វើដៃអាវដៃអីកាលណុងគាត់នេះក្រុងធ្វើក្រុងលក់ហើយនេះទៅចេះតែរស់ទៅនៅមួយថ្ងៃរស់មួយថ្ងៃ
រាល់ថ្ងៃរស់ដោយសារកូនតើរាល់ថ្ងៃ។

ក៖ អ៎!

ខ៖ កូនអោយចាយតើ!

ក៖ បាទតាបាទចុះគិតថាដល់ពេលពេលណាដែរតាគិតថាយើងចាប់ផ្តើមសប្បាយហាសតាយើងលែងមានការលំបាកអីទៀតហើយលែងមានសង្គ្រាមហាស?

ខ៖ តែប៉ុណ្ណឹងមានណាទេតែហូបបាយហើយទៅការហ្វេ។

ក៖ អត់ទេតែតាគិតថាឆ្នាំណាដែរតាគិតថាសប្បាយលែងមានសង្គ្រាមហាសតា?

ខ៖ ខ្ញុំតាំងពីណុងមកមានលំបាកអីធ្វើតែជាងសំណង់ហ្នឹងតែប៉ុណ្ណឹង។

ក៖ អ៎បាទតា តាធ្លាប់បានម៉្លេនពីមុនអត់តា?

ខ៖ អត់ទេពេលបែកអាពតម៉្លេនដែរចេះម៉្លេនពីគេពីឯងចឹងឃើញគេម៉្លេបឥដ្ឋយើងឆ្ពោតយើងមើលយូរៗទៅ
ហើយរាល់ថ្ងៃបានកូនមួយកូនគេធ្វើសំណង់ដែរហាសគេឆ្ពោតវាអត់អីវាម៉្លេបបុកឆ្ពោតៗជាងខ្ញុំឆ្ងាយហាស!

ក៖ ប៉ុន្តែតាធ្លាប់បានម៉្លេនអក្សរខ្មែរពីមុនអត់តាម៉្លេនបានថ្នាក់ទីប៉ុន្មាន?

ខ៖ ម៉្លេនថ្នាក់ទីប្រាំពីរដល់ទីប្រាំពីរពីសង្គមហាស!

ក៖ បាទតា!

ខ៖ ម៉្លេនអង់គ្លេសអីម៉្លេនបារាំងតាំងពីអាយុប្រាំបួនឆ្នាំ។

ក៖ អ៎តាំងចេះបារាំងទៀតហោស?

ខ៖ ចេះ!

ក៖ ប៉ុន្តែឥឡូវតាភ្លេចអស់ហើយណេះ?

ខ៖ ភ្លេចអស់ហើយចេះតែម៉្លេនទៅគេដាក់អោយម៉្លេន។

ក៖ អ៎ចុះតាគិតថាអីកាលតានៅម៉្លេនហាសតាធ្លាប់មានមិត្តភក្តិស្និទ្ធិស្នាលដែរធំធាត់មកជាមួយគ្នាអត់តា?

ខ៖ មានស្គាល់តែពួកណុងគេធ្វើមានគេធ្វើខគរបាលអីប៉ុនខ្ញុំអត់ធ្វើ។

ក៖ អ៎ចុះតាគិតថាតាធ្លាប់មានអនុស្សាវរីយ៍អីជាមួយមិត្តភក្តិតាអត់កាលតានៅក្មេងហាស?

ខ៖ ខ្ញុំមានធ្វើអីមានអាមួយជាងសំណង់អាមួយធ្វើខគរបាលផ្សេងទៅ។

ក៖ អ៎!

ខ៖ រាប់អានរាល់ថ្ងៃបានកូនចិញ្ចឹមរាល់ថ្ងៃក្នុងហ្នឹងប្រពន្ធខ្ញុំហ្នឹងកូនចិញ្ចឹមហើយយើងដាស្គអីប្រពន្ធខ្ញុំអាយហូបទៅ។

ក៖ អ៎!

ខ៖ ហ្នឹងខ្ញុំអង្គុយលេងរាល់ថ្ងៃតែប៉ុណ្ណឹងមានធ្វើអីទៀត។

ក៖ រួចចុះតាពីក្មេងតាធ្លាប់ធ្វើប៉ែ្រសចំការអត់តា?

ខ៖ ធ្វើចំការអ៎ពីដើមដែកប៉ោងប៉ោះ ដែកប៉ោងប៉ោះ ដែកត្រឡាច ប៉ោងប៉ោះហែងទាំងតោនហោស!

ក៖ អ៎!

ខ៖ គេធុងគេវាលបោតគេហាសដប់បោតចឹងប៉ោងប៉ោះមិនដូចឥឡូវទេប៉ោងប៉ោះស្រួលដាំសឹងងាប់។

ក៖ ធំៗហោសយាយ?

ខ៖ ធំៗណាស់ប៉ុននេះ។

ក៖ អ៎!

ខ៖ ឯងនៅជិតប៉ោងប៉ោះធំៗហាសឯងធ្វើពោតយកពូជពោតទៅ។

ក៖ អ៎បាទចុះតាគិតថាចឹងកាលពីដើមតាមានចំការខ្លួនឯងសំរាប់ធ្វើណេះតាណេះ?

ខ៖ ពុកខ្ញុំគាត់ធ្វើជាអ្នកភ្ជួរហាសពីដើមគេសំបូរនេះណាស់អូនអើយគាត់មិនបានក្រមិនបាច់ទេអាសោរប៉ុនមេដែមេជើងអីណាទេពីដើមសំបូរសឹងងាប់។

ក៖ បាទតា!

ខ៖ ហែងមិនបាច់ទេតានេះនៅស្គតហ្នឹងហែងពីដើមវាសំបូរមិនដូចឥឡូវវាពិបាករកដូចពីដើមណា។

ក៖ បាទ!

ខ៖ ពីដើមស្រួលសឹងងាប់។

ក៖ បាទតាចុះតាគិតថាតាំងពីក្មេងរហូតមកដល់ឥឡូវតាធ្លាប់ធ្វើការងារអីគេខ្លះតានៅក្នុងជីវិតតាហាស?

ខ៖ ខ្ញុំធ្វើតែជាងសំណង់។

ក៖ ធ្វើតែជាងសំណង់ទេណេះតាណេះ?

ខ៖ បាទតែរស់ស្រួលដែរវាអត់ពិបាកហាស ធ្វើជាងសំណង់ហ្នឹងផុតពីរឿងផុតនេះមកដល់ប៉ុលពតហើយពេលបែកប៉ុលពតហើយប៉ុលពតហ្នឹងយកប្រពន្ធធ្វើជាងសំណង់រហូត។

ក៖ អ៎ចុះកាលពីក្មេងតាធ្វើអីគេតា?

ខ៖ ធ្វើចំការ។

ក៖ ធ្វើតែចំការទេណេះតាណេះ?

ខ៖ អើចំការទៅ។

ក៖ ដល់ពេលចូលប៉ុលពតងាច់ប៉ុលពតមកបានធ្វើជាងសំណង់រហូត?

ខ៖ បាទ!

ក៖ អ៎បាទតាចុះចឹងតាធ្លាប់លក់ដូរអត់តាចឹង?

ខ៖ អត់ទេ!

ក៖ អត់ដែរលក់ដូរទេ?

ខ៖

ដឹងថាដែកក្រៅពីត្រឡាចតែប៉ុណ្ណឹងហើយត្រសក់ស្រូវអូនកាលពីដើមហោសគេធេវាយជ្រោះរបេះទងទៅលក់ទៅហែងគេយកធ្វើអីត្រសក់ប៉ុនភ្លៅយើងតាមានណាទេត្រសក់ស្រូវ។

ក៖ ចុះ...?

ខ៖ ហើយខ្ញុំដល់ពេលមានប្រពន្ធខ្ញុំដាំនៅនេះ។

ក៖ អ៎!

ខ៖ ដំឡូងឈើដាំដំឡូងឈើហើយហ្នឹង...!

ក៖ ចុះតាគិតថាអីជីវិតរបស់តាតាំងពីក្មេងរហូតមកដល់ឥឡូវមានការផ្លាស់ប្តូរអីគេខ្លះតា?

ខ៖ អត់ធ្វើតែចំការធ្វើជាងតែប៉ុណ្ណឹង។

ក៖ អត់មានការផ្លាស់ប្តូរអីទេណេះតាណេះ?

ខ៖ អត់តាំងពីក្មេរហូត។

ក៖ ចុះទាំងសុខភាព ជីវភាពឥឡូវម៉ែចដែរតា?

ខ៖ សុខភាពប៉ុណ្ណឹងរាល់ថ្ងៃហូបបាយហើយទៅធ្វើហូបការហូរហើយតែប៉ុណ្ណឹងបាយស្រូបទៅ។

ក៖ ប៉ុន្តែ...?

ខ៖ ហើយបង្អែមមួយហ្វាវប៉ុណ្ណឹង។

ក៖ តែតាអត់មានឈឺអីទេហោសតា?

ខ៖ អត់តែប៉ុណ្ណឹង។

ក៖ អ៎ូ!

ខ៖ តាភឿនឯងឈឺដែរគាត់សួរអាឈឺកំប៉ោកកំប៉ុកធម្មតារបស់យើងអាធឿងហ្នឹងអត់ទេ ទោះគ្រាន់ខ្ញុំឈឺរហូតខ្ញុំលែងហូបអីទាំងអស់។

ក៖ អ៎ូ!

ខ៖ កាលមុនហូបស្រាតាំងពីលើសឈាមមកលែង។

ក៖ អ៎ូតឡូវលែង...?

ខ៖ លែង!

ក៖ លែងហូបស្រាលែងអី?

ខ៖ លែងអស់កាលមុននៅហូបមិនបាច់ទេតាប៉ុនមេដើងក៏ហូបមួយហ្ម៊ឹកអាបីរយប្រាំរយរហូតបីរយពីររយរហូតខ្ញុំដាក់ប៉ុនដល់ពេលឥឡូវខ្ញុំឈប់ហើយ!

ក៖ អ៎ូបាទតាចុះតាគិតថាម្ហូបអីគេដែរតាចូលចិត្តហូបហាសតា?

ខ៖ រាល់ថ្ងៃតែប្រពន្ធធ្វើអោយហូបហូបទើបខ្ញុំទាល់ច្រកទឹកស៊ីអៀវគឺស្រូបទឹកក៏ហូបបានដែរ។

ក៖ ប៉ុន្តែចង់និយាយថាម្ហូបដែរតាចូលចិត្តម៉ងតាចូលចិត្តហូបអីគេ?

ខ៖ អើតែគេធ្វើអោយធ្វើអីស្ពអីហូបហ្នឹងទៅបានកូនស្រីមួយកូនប្រុសគេនោះតែ...!

ក៖ អ៎ូចុះកាលពីក្មេងតាធ្លាប់លេងល្បែងប្រជាប្រិយ៍អីដូចលក្ខណៈបោះអង្គុញ ចោលឈូង លាក់កន្សែងអីអត់តា?

ខ៖ ចេះ!

ក៖ តែតាធ្លាប់លេងពីមុនទេ?

ខ៖ ធ្លាប់លេងកាលណុងផ្ទះខ្ញុំពីដើមដីធំហាស!

ក៖ បាទ!

ខ៖ អ៎ូមនុស្សជុំៗគេវាំទេភូមិហ្នឹងប៉ុនខ្ញុំស៊ីឈ្នួលគេឈ្នួលគុយទាវគេពីដើមនៅក្មេង។

ក៖ បាទតា!

ខ៖ អាខោអាវពីដើមគេធោយខោអាវប៉ុនមាន់ចិញ្ចឹមបានហាសអូនអើយមាន់ពីដើមមានណាទេមិនដូចឥឡូវនេះ។

ក៖ អ៎ូចុះតាគិតថាតាចេះច្រៀងអត់តា?

ខ៖ ចេះតើពីសង្គមពីសង្គមអីច្រៀងរហូតច្រៀងរហូតអាភូមិហ្នឹងគេលេងកាលណុងគេលេងភ្នាល់គ្នា។

ក៖ អ៎ូ!

ខ៖ បោះអង្គុញភ្នាល់គ្នាពីដើម។

ក៖ បាទតា!

ខ៖ ខាងក្រុមចឹងទៅមួយក្រុមហ្នឹងហើយពួកបងស្រីខ្ញុំហ្នឹងស្អាតៗមួយក្រុមគេហើយពួកហ្នឹងល្បីប៉ុនអារត់រហូតសប្បាយរហូតសប្បាយ។

ក៖ អ៎ូ!

ខ៖ ខ្ញុំធ្វើតែជាងសំណង់បែកពីអាពតធ្វើជាងសំណង់រហូត។

ក៖ បាទតា!

ខ៖

អើតាមហ្នឹងពួកហ្នឹងបិតស្រាបិតស្រាទៅខ្ញុំចូលចិត្តលេងបាល់ពីក្មេងដល់ពេលនេះទៅឈប់លេងទៅកាលនៅក្មេងមិនបាច់បាល់បាទីគ្មានឧរណាលេងជាមួយខ្ញុំបានទេវាល្មមគប់ទៅ។

ក៖ អ៎ូ!

ខ៖ បាល់យើងក្រោមល្អណាស់។

ក៖ បាទតា!

ខ៖ តែសុខភាពនៅប៉ុណ្ណឹងអត់មានស្រកសាច់អីទេប៉ុណ្ណឹង។

ក៖ អ៎ូចុះតាគិតថាអើតាចូលចិត្តវាំដែរណោះតា?

ខ៖ ចូលចិត្តវាំ។

ក៖ អ៎ូ!

ខ៖ ពីដើមវាំល្មមៗលេងមិនឈ្នះខ្ញុំទេ។

ក៖ អ៎ូចុះតាគិតថាមានឧរណាគេមួយនៅក្នុងក្រុមគ្រួសារតាចេះលេងឧបករណ៍ភ្លេងអត់តា?

ខ៖ អត់!

ក៖ បងប្អូនកូនក្មួយអីអត់ចេះដែរ?

ខ៖ អត់ចេះអាមួយមិញអាណុងខាងអ៊ុតសក់អ៊ុតសក់ស្រីៗហាស!

ក៖ អ៎ូ!

ខ៖ រកលុយបានណាស់។

ក៖ អ៎ូបាទ!

ខ៖ រកលុយបានណាស់ណុងបានស្រីមួយក៏ប្រាំរៀលដប់រៀលវាតាមចិរបស់គេហាស!

ក៖ បាទតាចុះតាគិតថាអើផ្ទះរបស់តាកាលតានៅជាមួយឪពុកម្តាយដំបូងផ្ទះម៉េចដល់ពេលឥឡូវផ្ទះម៉េចដែរតា?

ខ៖ អានេះផ្ទះបុរាណនៅដែលរហូតទៅមានអីទៀត។

ក៖ អ៎ូ!

ខ៖ មាននៅណាទៀត។

ក៖ ចុះកាលនៅក្មេងតានៅផ្ទះបែបណាតា?

ខ៖ នៅផ្ទះស្រាប់តើ!

ក៖ អ៎ូចឹងតាំងពីក្មេងរហូតដល់ឥឡូវនៅផ្ទះហ្នឹងដដែលហាស?

ខ៖ នៅផ្ទះដដែល។

ក៖ អ៎ូចុះតាគិតថាជំនាញអីដែរតាចេះស្មាត់ជំនាញតា?

ខ៖ រាល់ថ្ងៃមានធ្វើអីទេហូបបាយគេធ្វើអោយហូបទៅ។

ក៖ ចឹងមានន័យថាជំនាញតាហូបតែបាយទេ ចង់និយាយថាតាចេះធ្វើអីដែរតាចេះស្មាត់ម៉ងហាសអូចធ្វើប៉ែស្រីមួយធ្វើចំការ?

ខ៖ អត់ទេ!

ក៖ ធ្វើអីមួយចឹងហាស?

ខ៖ ធ្វើពីដើមគេដាំដំឡូងដាំអីដល់ពេលឈប់ដាំដំឡូងទៅឈប់ធ្វើអីទាំងអស់រាល់ថ្ងៃ។

ក៖ រួចចុះឪពុកម្តាយតាធ្លាប់បង្រៀនពីជំនាញអីទៅតាអត់?

ខ៖ មានតែជួយភ្ជួរដីជាមួយគាត់ហ្នឹងពីដើមមានធ្វើអីប៉ុនពីដើមវាសំបូរហាស!

ក៖ អ៎ូ!

ខ៖ ពីដើមសំបូរត្រីហើយខ្យងប៉ុនៗនេះយើងមិនគួរធ្វើមិនបាច់ទេ។

ក៖ បាទចុះតាគិតថាអើកាលពីនៅក្មេងតាធ្លាប់មានគោលបំណងថាតាធំឡើងតាចង់ធ្វើអីអត់ពេលតានៅរៀនហាសតាចង់ធ្វើគ្រូពេទ្យវិមួយប៉ូលីស វិមួយក៏អីចឹងតាធ្លាប់អត់?

ខ៖ ដែរកាលម៉ែចឹងទៅតែធ្វើចំការរហូត។

ក៖ អ៎ូបាទចុះបើសិនជាចង់អោយតាផ្លែផ្កាំទៅកូនចៅរបស់តាជំនាន់ក្រោយៗតាគិតថាចង់ផ្លែផ្កាំអីទៅពួកគាត់ដែរតា?

ខ៖ អត់មានផ្លែផ្កាំទេទៅតាមដំណើរទៅបានប៉ុន្មានហូបប៉ុណ្ណឹងទៅហើយធ្វើតាមដំណើរកូនបានកូនមានគ្រាន់បើមីពៅគេវារៀនអីប្រលងជាប់វាធ្វើគ្រូក្មេងៗទៀត។

ក៖ អ៎ូ!

ខ៖ ពៅគេហាស!

ក៖ បាទ!

ខ៖ ជិតរៀបវាហើយតែថ្ងៃខែវាអត់ល្អគេអត់ទាន់រៀបទៅ។

ក៖ បាទតា!

ខ៖ ហើយរាល់ថ្ងៃបានវាហ្នឹងអោយលុយខ្វះលុយអីបានវាទៅមើលអញ់ពីរពាន់ធីកកាហ្វេវាអោយហើយតែប៉ុណ្ណឹង។

ក៖ ចុះ...?

ខ៖ ខ្ញុំជក់អាថ្នាំខ្លាំងរាល់ថ្ងៃជក់តែអាសុទ្ធដែរហែងជក់អីជក់ទៅប៉ុណ្ណឹងវាថាប៉ុណ្ណឹង។

ក៖ បាទតាចុះអ៎ូចឹងចុះបើសិនជាតាចង់អោយកូនចៅជឿសម្បឹងវិញហាសតាគិតថាចង់អោយជឿសពីអំពើអីអូចលក្ខណៈជក់គ្រឿងញៀនអី?

ខ៖ អត់ទេអត់មាននរណាចេះជក់ទេ។

ក៖ ប៉ុន្តែអាហ្នឹងយើងលក្ខណៈយើងអោយគាត់ជឿសម្បឹងហាសតា?

ខ៖ បាទ!

ក៖ ចឹងតាមានអីដែរចង់ផ្លែផ្កាំផ្សេងទៀតអត់តា?

ខ៖ អត់ទេ។

ក៖ ចឹងហោសតាចឹងប្រហែលចៅអរគុណតាដែរបានអោយចៅពិភាក្សាទាក់ទងពីប្រវត្តិរបស់តាចឹងហាសតាបាទតា។